# សម្តេចតេជោ **ហ៊ុន សែន** បានសម្រេចប្រគល់សិទ្ធកាន់កាប់ដីធ្លីស្របច្បាប់ ចំនួន០៤ទីតាំងបន្ថែមទៀតជូនប្រជាពលរដ្ឋ ក្នុងពិធីសម្ពោធប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅទីរួមខេត្តបាត់ដំបង

នាព្រឹកថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០១៦ ដើម្បីជាចំណងដៃនៅថ្ងៃសម្ពោធដាក់ឲ្យដំណើរការប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅទីរួមខេត្តបាត់ដំបង **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចប្រគល់សិទ្ធកាន់កាប់ដីធ្លីស្របច្បាប់ ចំនួន០៤ទីតាំងបន្ថែមទៀត ជូនប្រជាពលរដ្ឋ ចំនួន១៤៩គ្រួសារ ដែលកំពុងរស់នៅលើដីកម្មសិទ្ធសាធារណៈរបស់រដ្ឋនៅក្នុងខេត្តបាត់ដំបង តាមរយៈឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បន្ទាប់ពីបានសម្រេចប្រគល់ ជូនមួយទីតាំងរួចមកហើយនៅក្នុងបុរីកម្មករ នៃរោងចក្រត្បាញសំពត់ ខេត្តបាត់ដំបង ជូនប្រជាជនចំនួន ៤៩គ្រួសារកាលពីពេលថ្មីៗ កន្លងទៅនេះ។

សូមជំរាបផងដែរថា ផ្ទៃដីទាំង០៤ទីតាំងបន្ថែមដែលនឹង ត្រូវប្រគល់សិទ្ធកាន់កាប់ ស្របច្បាប់ជូនប្រជាពលរដ្ឋ នៅពេលនេះគឺជា ដីកម្មសិទ្ធសាធារណៈរបស់រដ្ឋ ស្ថិតក្នុងបញ្ជីសារពើភ័ណ្ឌរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ គិតចាប់តាំងពីឆ្នាំ ១៩៧៩ មកទល់បច្ចុប្បន្នពួកគាត់ដែលភាគច្រើនជាអតីតគ្រួសារកម្មករ បានរស់នៅលើដីនេះ ដោយមិនមានឯកសារស្របច្បាប់ណាមួយដើម្បីធានានូវនិរន្តរភាព នៃទីជម្រករបស់ពួកគាត់ឡើយ ព្រោះដីនេះជាកម្មសិទ្ធរបស់រដ្ឋ។

ដោយមើលឃើញពីតម្រូវការចាំបាច់ និងកង្វល់របស់បងប្អូនប្រជាពលរដ្ឋ ទាំង១៤៩ គ្រួសារ និងដោយទទួលបាននូវរបាយការណ៍ ជាក់លាក់ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម **សម្តេចតេជោ** នាយករដ្ឋមន្ត្រី បានសម្រេចប្រគល់សិទ្ធកាន់កាប់ ស្របច្បាប់ជូនពួកគាត់ទាំង ១៤៩គ្រួសារ ដែលក្នុងនោះរួមមាន៖

១-ទីតាំងដីអតីតពហុសិប្បកម្ម នៅភូមិអូរតាគាំ១ សង្កាត់ទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង លើផ្ទៃដីទំហំ ៧.០៩០ម៉ែត្រការ៉េ ជូនប្រជាពលរដ្ឋចំនួន ៩៧គ្រួសារ។
២-ទីតាំងគម្រោងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត (វត្តលាប) និងជាទីតាំងអតីតរោងចក្រទឹកកកទឹកក្រូច ស្ថិតនៅភូមិវត្តលាប សង្កាត់ចំការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង លើផ្ទៃដីទំហំ ១.៣៧៩ម៉ែត្រការ៉េ ជូនប្រជាពលរដ្ឋចំនួន ២៤គ្រួសារ។

៣-ទីតាំងអតីតរោងសិប្បកម្មស្ករអំពៅ ស្ថិតនៅភូមិដំណាក់ល្ហុង សង្កាត់វត្តគរ ក្រុងបាត់ដំបង ខេត្តបាត់ដំបង លើផ្ទៃដីទំហំ ៣.២៤៦ ម៉ែត្រការ៉េ ជូនប្រជាពលរដ្ឋចំនួន ២៧គ្រួសារ។
៤-ទីតាំងបរិវេណអង្គភាពរដ្ឋាករទឹកបាត់ដំបង ស្ថិតនៅភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង លើផ្ទៃដីទំហំ ៥៦០ម៉ែត្រការ៉េ ក្នុងនោះដីទំហំ ២៨០ម៉ែត្រការ៉េ ផ្តល់ជូនកម្មករមួយគ្រួសារ និងដីទំហំ ២៨០ម៉ែត្រការ៉េទៀត សម្រាប់ដោះស្រាយគោលនយោបាយ ជូនកម្មករដែលមានការពាក់ព័ន្ធ។

គួររំឭកផងដែរថា នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ ម្សិលមិញបន្ទាប់ពីបានអញ្ជើញចុះសួរសុខទុក្ខជាមួយប្រជាពលរដ្ឋចំនួន ៤៩ នៅបុរីកម្មករ នៃរោងចក្រត្បាញសំពត់ ដែលទើបទទួលបាន ការឯកភាពថ្មីៗ ពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** នូវកម្មសិទ្ធស្របច្បាប់ លើផ្ទៃដីរដ្ឋចំនួន ៥.៧៧១ម៉ែត្រការ៉េរួចមក ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក៏បានអញ្ជើញចុះជួបផ្ទាល់ផងដែរ ជាមួយបងប្អូនប្រជាពលរដ្ឋនៅ ០៤ទីតាំងខាងលើ ហើយ លោកបានពាំនាំនូវប្រសាសន៍ផ្តាំសួរសុខទុក្ខ និងការនឹករលឹកពីសំណាក់ **សម្តេចតេជោ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជូនចំពោះបងប្អូនប្រជាពលរដ្ឋទាំងអស់គ្នា និងបានជម្រាបប្រាប់បងប្អូនអោយរស់នៅ និងរកទទួលទាន ដោយស្ងប់អារម្មណ៍ កុំមានការព្រួយបារម្មណ៍ចំពោះ ការបាត់បង់លំនៅដ្ឋានរបស់ខ្លួន ព្រោះពេលនេះ ក្រោមការគិតគូ និងយកចិត្តទុកដាក់ ពី **សម្តេចតេជោ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បងប្អូនប្រជាពលរដ្ឋគឺបានទទួលនូវសិទ្ធស្របច្បាប់លើការកាន់កាប់ដីធ្លី ដែលខ្លួនកំពុងរស់នៅ និងប្រកបរបរចិញ្ចឹមជីវិតជាប្រចាំថ្ងៃ។

បន្ទាប់ពីទទួលបាននូវដំណឹងដ៏ល្អនេះ បងប្អូនប្រជាពលរដ្ឋទាំង ១៤៩គ្រួសារ បានសម្តែងនូវសេចក្តីរីករាយជាពន់ពេកក្រៃលែង និងបានថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅ ជាទីបំផុត តាមរយៈ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ជូនចំពោះ **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលសម្តេចទាំងពីរ តែងគិតគូពីសុខទុក្ខ របស់ប្រជាពលរដ្ឋ និងដោះស្រាយបញ្ហាជូនពួកគាត់ គ្រប់កាលៈទេសៈ ហើយនិងបានជូនពរ សម្តេចទាំងពីរ ទទួលបាននូវសុខភាពល្អ កម្លាំងពលាំងមាំមួន ដើម្បីបន្តដឹកនាំប្រទេសជាតិ អោយកាន់តែរីកចម្រើនទៅមុខ។